**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**អគ្គនាយកដ្ឋានយោធសេវា**

លេខៈ.............................

# សេចក្តីប្រកាសព័ត៌មាន

យោងតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ(អ.ស.ប) រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតជូនគណៈកម្មាធិការជាតិ បញ្ជូនកងកម្លាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ចំនួន០៣កង រួមមានដូចខាងក្រោម ៖

១.កងវិស្វកម្មព្រលានយន្តហោះលេខ១៩៨ ចំនួន១៦៥នាក់ ទៅកាន់សាធារណរដ្ឋម៉ាលី

២.កងកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ១៣២ ចំនួន១៤៤នាក់ ទៅកាន់សាធារណរដ្ឋម៉ាលី

៣.កងអាវុធហត្ថលេខ៦៨១ ចំនួន១១៩នាក់ ទៅកាន់សាធារណរដ្ឋស៊ូដង់ខាងត្បូង។

ពិធីនេះ នឹងប្រព្រឹត្តទៅនាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង០៨:០០នាទី ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមូលដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ ។

ថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៨